# ព្រឹត្តិបត្រព័ត៌មាន

## គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូច នៅតំបន់ទន្លេសាប ( ធី.អេស.អេស.ឌី )

*ផ្តល់ថវិកាអនុវត្តដោយៈ ធនាគារអភិវឌ្ឍន៍អាស៊ី មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម រដ្ឋាភិបាលហ្វាំងឡង់ និង រាជរដ្ឋាភិបាលកម្ពុជា*

**គម្រោងទន្លេសាប ធី.អេស.អេស.ឌីៈ** ជួយកែលម្អជីវភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ប្រមាណជា ៦៣ម៉ឺនគ្រួសារ ក្នុង១៩៦ឃុំ ២៨ស្រុក ក្នុងខេត្ត បន្ទាយមានជ័យ សៀមរាប កំពង់ធំ កំពង់ចាម និង ត្បូងឃ្មុំ តាមរយៈ ( ១ ) ការកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទគាំទ្រដល់ផលិតភាពកសិកម្ម ( ២ )ការបង្កើនសមត្ថភាពបច្ចេកទេសរបស់កសិករខ្នាតតូច ( ៣ ) ការផលិត-ផ្គត់ផ្គង់ពូជដំណាំមានគុណភាព និង ( ៤ ) ការផ្តល់ព័ត៌មានដល់កសិករ។

## មាតិកាសម្រាប់ត្រីមាសទី ៣ ឆ្នាំ ២០១៤


១. ប្រព័ន្ធស្រោចស្រពខ្នាតតូច ជួយកសិករក្រីក្របង្កើនផលិតភាពកសិកម្ម (ដោយ KPC-PPMA)

២. ការអនុវត្តបច្ចេកទេសថ្មី លើដីចាស់ បានផលស្រូវគួរជាទីពេញចិត្ត (ដោយ SRP-PAEA )

៣. ទុនបង្វិលក្រុម ជួយសមាជិកលីគ កែលម្អជីវភាពគ្រួសារ ស្របតាមស្ថានភាពរបស់គាត់ (ដោយ SRP-LICA)

៤.ដាំបន្លែត្រសក់ទ្រើងតាមបច្ចេកទេស បង្កើនប្រាក់ចំណូលបួនដង (ដោយ BMC-PAEA )

៥. ទុនបង្វិលក្រុមកែលម្អជីវភាព ជួយគ្រួសារក្រីក្រ ឲ្យចាប់ផ្តើមបង្កើតរបរថ្មី ផ្តល់ចំណូលច្រើន - ការចិញ្ចឹមកង្កែប (ដោយ BMC-LICA)

៦. ទុនបង្វិលក្រុមលីគ អាចជួយគ្រួសារក្រីក្រ បង្កើនប្រាក់ចំណូលទ្វេដង ពីរបរក្រៅកសិកម្មខ្នាតតូច (ដោយ KPT-LICA)


### ១. ប្រព័ន្ធស្រោចស្រពខ្នាតតូច ជួយកសិករក្រីក្របង្កើនផលិតភាពកសិកម្ម

លោក *ឈឹម យន* អាយុ ៥៦ឆ្នាំ ជាកសិកររស់ក្នុងភូមិសង្កែ ឃុំស្តើងជ័យ ស្រុកជើងព្រៃ មានកូន ៨នាក់ ស្រី២នាក់ ប្រុស៦នាក់ តែសព្វថ្ងៃមានតែ២នាក់ទេ ចិតក្រោមបន្ទុករបស់គាត់។ សព្វថ្ងៃក្នុងគ្រួសាររបស់គាត់ មានសមាជិក៦នាក់ ក្នុងនោះកូន២នាក់ និង ចៅ២នាក់។ គាត់មានផ្ទៃដីស្រែ ១ហិកតា កន្លះ និងដីលំនៅដ្ឋានតិចតួច។ គាត់ជាសមាជិកក្រុមកែលម្អជីវភាព (លីគ) ដែលទើបបង្កើតក្នុងត្រីមាសទី៣ ឆ្នាំ២០១៤ នេះ តែមិនទាន់បានទទួលទុនបង្វិលក្រុមនៅឡើយ។ នៅរដូវវស្សា គាត់ធ្វើស្រែ ដោយប្រើពូជស្រូវក្នុងស្រុក (ផ្កាម្លិះ ក្រោកពង់ និង រាំងជ័យ) លើផ្ទៃដីដែលគាត់មានទាំងអស់ ហើយបានផល ប្រមាណ ពី១២០ ទៅ ១៣០ថាំង (ពី ២,៨តោន ទៅ ៣តោន) ក្នុងមួយឆ្នាំ ក្នុងនោះគាត់ទុកហូបប្រហែលពាក់កណ្តាល ហើយស្រូវនៅសល់ លក់។ នៅរដូវ ប្រាំង គាត់ធ្វើស្រូវប្រាំងតិចតួច ដោយគ្មានទឹកគ្រប់គ្រាន់ និងគ្មានប្រភពទឹក នៅក្បែរ។ ក្រៅពីស្រូវ គាត់បានដាំដំណាំរួមផ្សំ ដូចជា ឪឡឹក ត្រសក់ស្រូវ និងបន្លែខ្លះៗ ជាចំណូលបន្ថែមសម្រាប់គ្រួសារ។ ដំណាំឪឡឹក ផ្តល់ចំណូលចំបងសម្រាប់គ្រួសារគាត់នៅរដូវប្រាំង បានប្រាក់ប្រមាណពី ៣ ទៅ ៤ លានរៀល ក្នុងនោះបានចំណេញសុទ្ធពី ១លាន ទៅ១លានកន្លះ អាស្រ័យលើតម្លៃជីគីមី និងទីផ្សារតម្លៃផ្លែឪឡឹក។





នៅឆ្នាំ ២០១៤ នេះ គាត់មានសេចក្តីរីករាយយ៉ាងខ្លាំង ដោយគម្រោងបានធ្វើការជួសជុលប្រឡាយមួយខ្សែ និងទ្វារទឹក ក្នុងតំបន់របស់គាត់ ដែលអាចជួយដល់កសិករប្រមាណពី ២០០ ទៅ ៣០០គ្រួសារ មានផ្ទៃដីស្រែសរុបពី ៣០០ ទៅ៤០០ហិកតា នៅក្បែរប្រឡាយ។ មុនពេលប្រឡាយនេះជួសជុល មានគ្រួសារមួយចំនួនតូច (ប្រហែល១០គ្រួសារ) ធ្វើស្រូវប្រាំង មានផ្ទៃដីសរុបពី ៥ ទៅ ១០ហិកតា ដោយសារគ្មានទឹកគ្រប់គ្រាន់ ហើយប្រឈមនឹងភាពប្រថុយប្រថានខ្ពស់។

ដោយសារមានទ្វារទឹកដូច្នេះ នៅរដូវទឹកស្រក (អស់ទឹកភ្លៀង) អ្នកភូមិនឹងអាចតម្កល់ទឹកទុកប្រើប្រាស់បាន។ គាត់សង្ឃឹមថា នៅឆ្នាំក្រោយប្រាកដជាមានគ្រួសារជាច្រើននឹងចាប់ផ្តើមធ្វើស្រូវប្រាំង ឬ ស្រូវមិនប្រកាន់រដូវ ឬ ដំណាំចំការ នៅដើមរដូវវស្សា។ ក្នុងនោះគ្រួសាររបស់គាត់ក៏នឹងពង្រីកការធ្វើស្រែប្រាំងបន្ថែមផងដែរ ក្រៅពីឪឡឹក ត្រសក់ស្រូវ ដើម្បីបង្កើនប្រាក់ចំណូល។ លើសពីនេះ គាត់អាចទាញយកទឹកពីប្រឡាយនេះ សម្រាប់ស្រោចដំណាំជុំវិញផ្ទះរបស់គាត់ និងសម្រាប់សត្វពាហនៈផងដែរ។ គាត់សង្ឃឹមយ៉ាងមុតមាំថា គ្រួសារគាត់ និងគ្រួសារកសិករមួយចំនួនធំក្នុងមូលដ្ឋានគាត់ នឹងទទួលបានផលប្រយោជន៍ច្រើនពីប្រឡាយថ្មីនេះ៕

## ២. ការអនុវត្តបច្ចេកទេសថ្មី លើដីចាស់ ឬានផលស្រូវគួរជាទីពេញចិត្ត

លោក *ឡេ វិច* អាយុ៦៥ឆ្នាំ រស់នៅភូមិក្រសាំង សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប។ គាត់មានកូន ៦នាក់ (ប្រុស៥ ស្រី១) តែសព្វថ្ងៃ មានតែ២នាក់ រស់នៅជាមួយគាត់ និង ប្រពន្ធគាត់ ឈ្មោះ អ៊ុត សំ អាយុ៦២ឆ្នាំ។ គ្រួសារគាត់មានជីវភាពរស់នៅបង្គួរ ពីការងារកសិកម្ម (ធ្វើស្រែ និងដំណាំរួមផ្សំ) លើផ្ទៃដីសរុប ២ហិកតា។ ការធ្វើស្រែរបស់គាត់ អនុវត្តតាមទំលាប់ រៀនតៗគ្នាពីកសិករផ្សេងទៀតក្នុងភូមិគាត់ ហើយឆ្នាំកន្លងទៅប្រើពូជស្រូវស្រាល (សែនពិដោរ) ចែកពូជតៗគ្នា ប្រើពូជច្រើនដល់ទៅ ៨០គីឡូ ក្នុង១ហិកតា ដោយស្ទូងចាប់៤-៥ដើម ក្នុង១គុម្ព តែទទួលបានផលប្រមាណ ២តោន ក្នុង១ហិកតា។ នៅរដូវវស្សា ឆ្នាំ ២០១៤នេះ គាត់បានចូលរួមជាមួយគម្រោង ក្នុងការធ្វើបង្ហាញបច្ចេកទេសប្រពលវប្បកម្មដំណាំស្រូវ លើផ្ទៃដី ២.០០០ម៉ែត្រការ៉េ ដោយប្រើពូជមានគុណភាព (ពូជ សែនពិដោរ) ប្រើពូជចំនួន ៥គីឡូ (គឺថា ២៥គីឡូ ក្នុង១ហិកតា) និង ជី តាមបច្ចេកទេស (បរិមាណ និង ពេលវេលា) ព្រមទាំង ការគ្រប់គ្រងដំណាំតាមបច្ចេកទេស។ បន្ទាប់ពីអនុវត្តតាមបច្ចេកទេសណែនាំរបស់មន្ត្រីក្រុមគាំទ្របច្ចេកទេសកសិកម្មក្រុងសៀមរាប មួយរដូវពេញមក នៅចុងខែកញ្ញានេះ គាត់បានប្រមូលផលពីស្រែបង្ហាញរបស់គាត់ បានផលស្រូវ ១.១០១គីឡូ ពីដីធ្វើបង្ហាញ ២.០០០ម៉ែត្រការ៉េ របស់គាត់។ ផលទទួលបាននេះ គិតជាទិន្នផលទៅ មានប្រមាណជា ៥តោនកន្លះ ក្នុង ១ហិកតា។ ទិន្នផលនេះ បានកើនឡើងប្រមាណជា ២ដងកន្លះ ធៀបនឹងទិន្នផលទទួលបាន តាមទំលាប់ធ្វើស្រែរបស់គាត់។



ដោយទទួលបានលទ្ធផលជោគជ័យបែបនេះ លោក *ឡេ វិច* បានអះអាងថា កម្មវិធីគាំទ្របច្ចេកទេសរបស់នេះ បានផ្តល់ឲ្យគាត់នូវចំណេះដឹងថ្មី និងបទពិសោធន៍ល្អៗសម្រាប់កែលម្អផលិតកម្មដំណាំស្រូវ របស់គាត់យ៉ាងមានប្រសិទ្ធភាព ដោយទទួលបានទិន្នផលខ្ពស់ ជួយឲ្យគ្រួសារគាត់បង្កើនជីវភាពកាន់តែប្រសើរ។ គាត់បានសន្យាថា នឹងចែករំលែកបន្ត ទាំងពូជស្រូវ និង ចំណេះដឹងបទពិសោធន៍បច្ចេកទេស ដែលទទួលបាន ដល់កសិករដទៃទៀត៕

## ៣. បង្វិលក្រុម ជួយសមាជិកលីគ កែលម្អជីវភាពគ្រួសារ ស្របតាមស្ថានភាពរបស់គាត់ទុន

លោកស្រី *ជួន អាន* អាយុ៣៤ឆ្នាំ មានកូន៣នាក់ មានទីលំនៅភូមិអញ្ចាញ ក្នុងសង្កាត់ នគរភ្នំ ក្រុងសៀមរាប ជាអនុប្រធានក្រុមកែលម្អជីវភាព (លីគ) មានសមាជិកសរុបចំនួន២៥នាក់ (ស្រី៤នាក់)។ ជាកសិករប្រភេទក្រ-១ គ្រួសារគាត់ មានជីវភាពដុនដាប មុនចូលក្រុមលីគ។ បន្ទាប់ពីបានចូលក្នុងក្រុមលីគ កាលពីខែកក្កដា ឆ្នាំ២០១៤មក គាត់បានខ្ចីប្រាក់ចំនួន៤០ម៉ឺនរៀល ពីទុនបង្វិលរបស់ក្រុម។ គាត់បានបែងចែកប្រាក់នោះ ជាពីរ ពាក់កណ្តាលសម្រាប់ចិញ្ចឹមមាន់ ហើយពាក់កណ្តាលទៀត សម្រាប់ដាំបន្លែសណ្តែកកួរលើដីទំហំ ២០ម៉ែត្រ x ៣០ម៉ែត្រ។



គាត់បានទិញមាន់តូចធំចំនួន២០ក្បាល ក្នុងនោះមានមេពូជចំនួន៥ក្បាល ធ្វើរោងមាន់១ និង ទិញចំណីបាវ ៥គីឡូ សម្រាប់លាយជាមួយចំណីមានស្រាប់ (កន្ទក់ ចុងអង្ករ សំណល់ផ្ទះបាយ..) សម្រាប់បំប៉នមាន់របស់គាត់។ គាត់បានទទួលបច្ចេកទេសចិញ្ចឹមមាន់ និង ដាំសណ្តែកកួរ តាមរយៈការសួរនាំជាប្រចាំពីមន្ត្រីកសិកម្មក្រុងសៀមរាប ពិសេស ពីមន្ត្រីផ្សព្វផ្សាយសង្កាត់។



គាត់ចាប់ផ្តើមទទួលផលពីការចិញ្ចឹមមាន់របស់គាត់។ មកដល់ចុងខែកញ្ញា ឆ្នាំ២០១៤ នេះ បានលក់មាន់ចំនួន ១៥ក្បាល បានប្រាក់ ២៧ម៉ឺន ៥ពាន់រៀល ហើយគ្រោងនឹងលក់ចំនួន១០ក្បាលទៀត នៅចុងខែតុលានេះ ដើម្បីទិញសម្ភារៈសិក្សាឲ្យកូន ពេលចូលបវេស្សកាលវិញ និងទុកខ្លះសម្រាប់ពង្រីកការចិញ្ចឹមមាន់របស់គាត់ ដោយទិញមេពូជបន្ថែម ៥ក្បាលទៀត។

រីឯដំណាំសណ្តែកកួរវិញ គាត់ប្រមូលផលសរុបបានប្រមាណជា ១៨០គីឡូក្រាម ហើយលក់បានប្រាក់ ២២ម៉ឺន រៀល។ នៅពេលខាងមុខនេះ គាត់ត្រៀមនឹងពង្រីកផ្ទៃដីដាំសណ្តែកនេះបន្ថែមចំនួន ២០០ម៉ែត្រការ៉េ ទៀត។

ការអនុវត្តជាក់ស្តែង ដោយមានការគាំទ្របច្ចេកទេសពីគម្រោង ធ្វើឲ្យគាត់ទទួលបានបទពិសោធន៍ និង មានជំនឿទុកចិត្តលើការចិញ្ចឹមមាន់ និងការដាំសណ្តែកកួរ។ គាត់បានមានប្រសាសន៍ថា *"ខ្ញុំមានជំនឿយ៉ាងមុតមាំ ក្នុងការកែប្រែជីវភាពគ្រួសារខ្ញុំបានប្រសើរជាងមុន ដោយខិតខំប្រឹងប្រែងពង្រីកការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ និង ដាំសណ្តែកកួររបស់ខ្ញុំ"* ។

ដោយឃើញគាត់ទទួលបានជោគជ័យក្នុងការចិញ្ចឹមមាន់ សមាជិកផ្សេងទៀតនៅក្នុងក្រុមលីគ ក្នុងភូមិនេះ បានផ្លាស់ប្តូរចិត្តពីចង់ចិញ្ចឹម ជ្រូក និង គោ មកជាចិញ្ចឹមមាន់ វិញ៕

## ៨. ដាំបន្លែត្រសក់ទ្រើងតាមបច្ចេកទេស បង្កើនប្រាក់ចំណូលបួនដង

អ្នកស្រី *អ៊ុក សារឿត* ជាកសិករ រស់នៅភូមិតាវង ឃុំពន្លៃ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ មានសមាជិកគ្រួសារ ៣នាក់ (ស្រី ១នាក់)។ គ្រួសារគាត់ធ្វើស្រែ ចិញ្ចឹមសត្វ និងដាំបន្លែ ដើម្បីផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ។ មុនចូលរួមជាមួយគម្រោង គាត់បានដាំបន្លែ ត្រសក់ទ្រើង សណ្ដែកកួរ ត្រកួន ត្រប់ ល្ពៅជាដើម។ ការដាំដំណាំទាំងនេះ ទទួលបានផលតិច ដោយសារតែ ដាំតាមទំលាប់ មិនបានអនុវត្តតាមបច្ចេកទេសត្រឹមត្រូវ តាមការរៀនធ្វើតៗគ្នាតែប៉ុណ្ណោះ។ ការដាំត្រសក់តាមទំលាប់លើផ្ទៃដី ៣០០ម៉ែត្រការ៉េ គាត់ទទួលបានផលប្រមាណ ៣០០គីឡូក្រាម ហើយរយៈពេលប្រមូលផល បានតែមួយសប្ដាហ៍អស់ផ្លែ ដោយទទួលបានចំណូលប្រមាណជា ៣០ ម៉ឺនរៀល (ក្នុងនោះចំណាយអស់ប្រមាណ ១២ ម៉ឺនរៀល)។



ដើមឆ្នាំ ២០១៤ គាត់បានចូលរួមអនុវត្តបច្ចេកទេសជាមួយគម្រោង ដោយធ្វើជាកសិករបង្ហាញបច្ចេកទេសដាំត្រសក់ទ្រើង លើផ្ទៃដី ៣០០ម៉ែត្រការ៉េ ដោយអនុវត្តតាមបង្គំបច្ចេកទេសថ្មី តាមរយៈការប្រើពូជល្អ និង បច្ចេកទេសដាំនិងថែទាំ ក្នុងនោះមានទាំងការប្រើ ប្លាស្ទិចគ្របរង និងការស្រោសចស្រពដោយប្រពន្ធ័ដំណក់ទឹក។ ក្នុងការធ្វើបង្ហាញបច្ចេកទេសថ្មីនេះ មន្ត្រីគាំទ្រកសិកម្មស្រុកភ្នំស្រុក បានចុះមកបង្ហាត់បង្ហាញបច្ចេកទេសផ្ទាល់នៅចំការរបស់គាត់ ដូចជា ការប្រើប្រភេទពូជផ្ដល់ផលខ្ពស់ ការធ្វើជីកំប៉ុស្ដិ៍ ការរៀបចំល្បាយដីបណ្ដុះកូន របៀបបណ្ដុះកូន ការគ្របថង់ប្លាស្ទិចលើរង ការរៀបចំទ្រើង (ធ្វើពីដំណាញ់មង) ការរៀបចំតំឡើងប្រពន្ធ័ស្រោចស្រពដំណក់ទឹក ការថែទាំ ដាក់ជី និង ការប្រមូលផល។



ដោយអនុវត្តបានខ្ជាប់ខ្ជួនតាមបច្ចេកទេសថ្មី គាត់អាចបេះត្រសក់បានជារៀងរាល់ថ្ងៃ ក្នុងរយៈពេល ២៩ថ្ងៃដំបូង ហើយពេលត្រសក់ចាស់ដើមបន្តិច គាត់ប្រមូលផលរៀងរាល់ពីរថ្ងៃម្ដង បានចំនួនប្រមាណជា ១០លើកទៀត។ បរិមាណផលដែលគាត់ប្រមូលផលមួយលើកៗ មានពី ២៥ ទៅ ៤០គីឡូ ហើយផ្លែវាធំប៉ុនៗគ្នា ធ្វើឲ្យបានតម្លៃខ្ពស់ជាងត្រសក់ដាំកាលពីមុន។

ក្នុងមួយរដូវដាំដុះ មានរយៈពេលជិត៣ខែ គាត់បេះបានត្រសក់សរុប ប្រមាណ ១.២៦៥ គីឡូ លក់បានតម្លៃជាមធ្យម ១.៣០០ រៀល ក្នុង ១គីឡូ ហើយបានប្រាក់ចំណូលសរុបចំនួន ១.៦៤៤.៥០០រៀល។ គាត់បានចំណាយសរុប (មិនគិតពី ពលកម្មគាត់) សម្រាប់ការដាំត្រសក់លើកប្រមាណជា ៥៨ម៉ឺនរៀល ហើយបន្ទាប់ពីទូទាត់ចំណាយរួច គាត់នៅសល់ប្រាក់ចំណេញប្រមាណជា ១លាន ៦ម៉ឺន រៀល (ប្រមាណ ២៦៥ដុល្លារអាមេរិក) ក្នុងមួយរដូវនេះ។



ក្នុងពេលអនុវត្តការដាំត្រសក់តាមបច្ចេកទេសថ្មីនេះ មានកសិករក្នុងភូមិប្រមាណជា ១០នាក់ បានមកមើលសួរនាំពីបច្ចេកទេសថ្មីនេះ ហើយមានកសិករម្នាក់ក្នុងភូមិ បានអនុវត្តតាមបច្ចេកទេសដាំបន្លែរបៀបថ្មីនេះ សម្រាប់ដំណាំសណ្ដែកកួរ។ អ្នកស្រី បានមានប្រសាសន៍ថា *"ខ្ញុំរីករាយ និងសប្បាយចិត្តយ៉ាងខ្លាំង ក្រោយពីបានចេះដាំបន្លែដោយប្រើបច្ចេកទេសថ្មីនេះ ធ្វើឲ្យខ្ញុំចំណេញពេលតិចក្នុងការស្រោចស្រព ប្រើទឹកតិចជាងមុន មិនពិបាកថែទាំបោចស្មៅ ផ្លែបានច្រើន និងបេះបានច្រើនដងជាងមុន។ ខ្ញុំសូមអរគុណចំពោះគម្រោង ដែលបានផ្ដល់បច្ចេកទេសថ្មី និង សំភារៈមួយចំនួន ដល់គ្រួសារខ្ញុំ។ ខ្ញុំនឹងបន្តដាំបន្លែនេះ និងបន្លែផ្សេងទៀត ដើម្បីបង្កើនប្រាក់ចំណូលគ្រួសារ "។*

## ៩. ទុនបង្វិលក្រុមកែលម្អជីវភាព ជួយគ្រួសារក្រីក្រ ឲ្យចាប់ផ្ដើមបង្កើតរបរថ្មី ផ្ដល់ចំណូលច្រើន - ការចិញ្ចឹមកង្កែប

លោក *ផុន គឹមហាន* អាយុ៥៨ឆ្នាំ ប្រពន្ធឈ្មោះ រាំង សារ៉ឺយ មានកូនចំនួន៧នាក់ ជាគ្រួសារក្រីក្រកម្រិត១ និងមានទីលំនៅក្នុងភូមិកំព្រីង សង្កាត់ភ្នៀត ក្រុងសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ។ ដើម្បីទ្រទ្រង់ជីវភាពរស់នៅ គ្រួសាររបស់គាត់ប្រកបរបរច្រើនមុខ រួមមាន ចិញ្ចឹមមាន់ទា នេសាទត្រី ធ្វើស្រែ និង ដើរស៊ីឈ្នួលដាំ និងដកដំឡូងមី ដែលសរុបបានចំណូល គ្រាន់តែគ្រប់ចំណាយ (ប្រហែល ១លានរៀល ក្នុង១មួយខែ) លើ ម្ហូបអាហារ ការសិក្សារបស់កូន សំលៀកបំពាក់ អគ្គីសនី និង សំភារៈប្រើប្រាស់ផ្សេងទៀត។ ជាមធ្យម កាត់ចំណាយសព្វគ្រប់រួច គ្រួសារគាត់នៅសល់ប្រាក់ប្រមាណពី ៧ ទៅ ៨ម៉ឺនរៀល ក្នុង១ខែៗ។ ចំណូលនេះ មិនសមស្របសម្រាប់តម្រូវការគ្រួសារគាត់ទេ ដូច្នេះហើយគាត់ខំស្វះស្វែងរករបរបន្ថែម ដើម្បីសន្សំប្រាក់ទុកសម្រាប់ ការឈឺស្កាត់ ផ្ដល់ឲ្យកូនរៀនសូត្រ ព្រមទាំងតម្រូវការផ្សេងៗទៀត។



នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ គាត់បានចូលរួមក្នុងក្រុមកែលម្អជីវភាព (លីគ) ហើយត្រូវបានសមាជិកក្រុម មានគ្នា ២៧នាក់ (ស្រី២០នាក់) ជ្រើសរើសគាត់ធ្វើជាប្រធានក្រុមលីគ ក្នុងភូមិគាត់។ ដូចសមាជិកផ្សេងទៀតដែរ គាត់បានខ្ចីប្រាក់ពីក្រុម ចំនួន៤០ម៉ឺនរៀល មានការប្រាក់ ២% ខ្ចី រយៈពេល៦ខែ ពីថ្ងៃទី២៧ ខែមិថុនា ដល់ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤។ គាត់យកលុយខ្ចីទាំងអស់ ទិញកង្កែបពូជបានមេបា២គូ ហើយរួមផ្សំនឹងប្រាក់សន្សំរបស់គាត់ខ្លះទៀត រៀបចំអាងចិញ្ចឹមធ្វើពីតង់កៅស៊ូ ស្បៃនីឡុង និងទិញចំណីសម្រាប់សាកល្បងចិញ្ចឹមនិងភ្ញាស់កង្កែប។ គាត់បានរៀនវិធីចិញ្ចឹមនិងភ្ញាស់កូនកង្កែបនេះ

ពីកសិករម្នាក់ទៀតក្នុងភូមិគាត់ ដែលបានរៀនពីវិធីចិញ្ចឹមកង្កែប ពីគម្រោងបង្ហាញបច្ចេកវិទ្យាតំបន់ទន្លេសាប នៅឆ្នាំ២០១២ និងតាមរយៈការសួរនាំបន្ថែមមន្ត្រីបច្ចេកទេស រួមទាំងមន្ត្រីផ្សព្វផ្សាយសង្កាត់ផង។



មកដល់ចុងខែកញ្ញា ឆ្នាំ២០១៤នេះ បានរយៈពេល៣ខែហើយ ដែលគាត់បានចាប់សាកល្បងចិញ្ចឹមនិងភ្ញាស់កង្កែប ហើយបានទទួលលទ្ធផលល្អ គួរជាទីគាប់ចិត្ត ដោយបានលក់កូនកង្កែបចំនួន ៩.៥០០ក្បាល (បានប្រាក់ ៣.៣២៥.០០០រៀល) និង កង្កែបសាច់បានចំនួន ១៨៥ គីឡូក្រាម (បានប្រាក់ ១.៦០២.៥០០រៀល)។ ក្រៅពីនេះ គាត់ក៏បានសំរាំងទុកនូវកង្កែបជំទង់ៗ របស់គាត់ សម្រាប់បំប៉នទុកធ្វើបាមេពូជ ចំនួន ៦០គូ (បើគិតជា លុយ គឺ ១លាន ៨សែន រៀល)។ គាត់បានលក់កូនបង្កែបក្នុងតម្លៃ ៣៥០រៀល ក្នុង១ក្បាល ឲ្យទៅកសិករក្នុងភូមិ រួមទាំងសមាជិកក្នុងក្រុមលីគ របស់គាត់ផង និងកសិករនៅភូមិក្បែរៗ។ តម្លៃនេះ ទាបជាង កាលពី២ឆ្នាំមុន ដែលមានតម្លៃដល់ទៅ ៥០០រៀលក្នុង១ក្បាល ហើយត្រូវទៅដឹកដោយខ្លួនឯងពីកសិដ្ឋានភ្ញាស់កង្កែប នៅស្រុកអូរជ្រៅ។ ចំណែកបង្កែបសាច់ គាត់លក់ឲ្យអ្នកនៅផ្សារទីរួមខេត្ត តម្លៃពី៨ពាន់ ទៅ១ម៉ឺនរៀលក្នុង១គីឡូបង្កែបរស់។ គាត់បានប្រាប់ឲ្យដឹងថា មកទល់ពេលនេះ គាត់ទទួលបានប្រាក់ចំណេញពីរបរបន្ថែមថ្មីនេះ ចំនួន ៤លាន១ សែនរៀល ដោយចំណាយដើមទុនសរុប២លានកន្លះ ហើយបានចំណូល ៦លាន ៧សែនរៀល។ ការចិញ្ចឹមបានជោគជ័យនេះ បានទាក់ទាញការចាប់អារម្មណ៍របស់កសិករផ្សេងទៀត។ គាត់បានចែករំលែកបទពិសោធន៍ចិញ្ចឹមកង្កែបដល់កសិករជាង២០នាក់ ដែលក្នុងនោះមានអ្នកដែលមកទិញកូនកង្កែបពីគាត់ និង កសិករជិតខាងផ្សេងទៀត។ គាត់ក៏បានទទួលទស្សនកិច្ចសិក្សាដកពិសោធន៍ របស់បុគ្គលិកមកពីស្ថាប័ននានា ជិត២០នាក់ ផងដែរ។



នៅឆ្នាំក្រោយ គាត់នឹងពង្រីកកន្លែងចិញ្ចឹមជាមួយមេបាបង្កែប ដោយប្រើមេពូជ៦០គូ ដែលគាត់បានសំរាំងទុកឆ្នាំនេះ។ ទន្ទឹមនេះផងដែរ គាត់នឹងពង្រីកការចិញ្ចឹមបង្កែបយកសាច់ ដោយប្រើកូនពូជ ដែលភ្ញាស់បានរបស់គាត់៕

## ៦. ទុនបង្វិលក្រុមលីគ អាចជួយគ្រួសារក្រីក្រ បង្កើនប្រាក់ចំណូលទ្វេដង ពីរបរក្រៅកសិកម្មខ្នាតតូច

មីង *ហោ ហ៊ាត* ជាស្ត្រីមេម៉ាយក្រីក្រ មានកូន៣នាក់ រស់នៅភូមិឈូក ឃុំប្រឡាយ ស្រុកស្ទោង ខេត្តកំពង់ធំ។ គាត់មានរបរលក់នំបញ្ចុកលក់ក្នុងភូមិនៅពេលល្ងាច ដែលទទួលបានប្រាក់ចំណេញពី ៦ពាន់ ទៅ ១ម៉ឺន២ពាន់រៀល តែប៉ុណ្ណោះក្នុងមួយថ្ងៃ។ គាត់តែងតែស្រមៃចង់ពង្រីកមុខរបរលក់នំបញ្ចុករបស់គាត់ឲ្យកាន់តែធំបន្ថែមទៀត ដោយលក់ទាំងព្រឹកល្ងាច ប៉ុន្តែមិនមានដើមទុនដើម្បីពង្រីក ហើយក៏មិនដឹងថាអាចទៅខ្ចីប្រាក់ពីណា ថែមទាំងខ្លាច មិនអាចរកសងគេវិញរួច។ គាត់បានឲ្យដឹងថា "*ការខ្ចីលុយគេ ពិបាកណាស់ ដោយសារតែខ្ញុំត្រូវការខ្ចីតិច បើខ្ចីឈ្មួញក្នុងភូមិ គេទារការប្រាក់ពី ១០ ទៅ ១៥ភាគរយ ក្នុង១ខែ ហើយត្រូវមានរបស់មានតម្លៃ ដូចជា ប្លង់ដី ដាក់បញ្ចាំទៀយ។ ឯមីក្រូហិរញ្ញវត្ថុវិញ គេតម្រូវឲ្យខ្ញុំខ្ចីចាប់ពី ១លានរៀលឡើង និងដាក់ប្លង់ដីទៀត ហើយបើខ្ញុំខ្ចីរហូតដល់មួយលានរៀល ខ្ញុំគ្មានលទ្ធភាពបង់រំលោះគ្រប់ចំនួនប្រចាំខែទេ*"។



តាំងពីចូលក្រុមកែលម្អជីវភាព(លីគ) មក មីងបានខ្ចីទុនបង្វិលរបស់ក្រុមគាត់ ចំនួន ៤០ម៉ឺនរៀល សម្រាប់រយៈពេល ១ឆ្នាំ ដោយមានការធានាពីសមាជិក ៤នាក់ ក្នុងក្រុមរបស់គាត់ ដើម្បីពង្រីករបរលក់នំបញ្ចុករបស់គាត់។ គាត់បានទិញឆ្នាំងធំថ្មីសម្រាប់ស្លទឹកសម្លនំបញ្ចុកបានច្រើនជាងមុន ទិញចានថ្មចង្កឹះថ្មី ដែលទាក់ទាញអ្នកហូបឲ្យចាប់អារម្មណ៍ជាងមុន និង ទិញអង្រែកថ្មី មាំ អាចឲ្យគាត់រែកបានច្រើនជាងមុន។ លុយខ្ចីមួយចំនួនទៀត គាត់ទិញគ្រឿងសម្រាប់ស្លទឹកសម្លបានច្រើនជាងមុន ដែលធ្វើឲ្យគាត់អាចលក់បានច្រើន ពេញមួយព្រឹក និងជួនកាលអាចបន្តដល់ល្ងាច ។



ជាលទ្ធផលពីកិច្ចប្រឹងប្រែងក្នុងការពង្រីកមុខរបររបស់គាត់ មីងបានសម្រេចរកប្រាក់ចំណេញប្រចាំថ្ងៃ បានរហូតដល់ពីរដង (គឺពី ១ម៉ឺន៥ពាន់ ទៅ ២ម៉ឺន៥ពាន់ រៀល) ក្នុងមួយថ្ងៃ។ បច្ចុប្បន្ន ជាមធ្យមក្នុង១ខែ សល់ពីបង់ការ និងចំណាយផ្សេងៗ មីងអាចនៅសល់ប្រាក់ចំនួនប្រហែល ៣០ម៉ឺនរៀល លើសកាលពីមុនចូលជាមួយក្រុម ចំនួនពីរដង។ មីង បាននិយាយ ទាំងទឹកមុខញញឹម សប្បាយរីករាយថា "*តាមរយៈថវិកាក្រុមកែលម្អជីវភាពនេះ គ្រួសារខ្ញុំបានធូរធាជាងមុនច្រើន ហើយក្លាយជាអ្នកលក់នំបញ្ចុកល្បីក្នុងភូមិផង។ ខ្ញុំគិតថាគ្មានបញ្ហា ខ្ញុំពិតជាអាចរកថវិកាសម្រាប់សងក្រុមវិញបាន*"។ គាត់បានបន្ថែមទៀតថា ជីវភាពគ្រួសារគាត់ កាន់តែប្រសើរជាងមុនជាលំដាប់ បន្ទាប់ពីបានចូលក្រុមលីគមក ដោយគាត់អាចមានថវិកាគ្រប់គ្រាន់ដើម្បីទិញសម្ភារៈប្រើក្នុងផ្ទះ សំលៀកបំពាក់ និង សម្ភារៈមួយចំនួនទៀតសម្រាប់កូន និងខ្លួនគាត់ ព្រមទាំងមានលុយសល់ខ្លះដើម្បីពង្រីករបរលក់នំបញ្ចុករបស់គាត់បន្ថែមទៀត។ អ្នកមីង គ្រោងសង់រោងលក់នំបញ្ចុក និងតវ៉ាន់ចាបហួយបន្តិចបន្តួច នៅមុខផ្ទះគាត់ ដើម្បីលក់ឲ្យបានទាំងព្រឹកទាំងល្ងាច។ អ្នកមីង បានថ្លែងអំណរគុណដល់គម្រោងទន្លេសាប នេះ ដែលបានជួយគាំទ្រគ្រួសាររបស់គាត់៕

*យោបល់ និងទស្សនៈ ក្នុងអត្ថបទនេះ ជារបស់គម្រោង និង អ្នកបញ្ចេញយោបល់ផ្ទាល់ ដូច្នេះមិនសុទ្ធតែឆ្លុះបញ្ចាំងពីទស្សនៈរបស់ដៃគូអភិវឌ្ឍន៍ផ្តល់ថវិកាឡើយ*